**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

*****

ខ្ញុំបាទ ញាន សុមុន្និន្ទ

អ្នកស្រាវជ្រាវផ្នែកច្បាប់ អភិបាលកិច្ច និងការអភិវឌ្ឍ

**សូមគោរពជូន**

**ឯកឧត្តម អនុរដ្ឋលេខាធិការ ទទួលបន្ទុកគ្រប់គ្រងធនធានរ៉ែមាស នៃក្រសួងរ៉ែ និងថាមពល**

កម្មវត្ថុ ៖ សំណើសុំព័ត៌មានពាក់ព័ន្ធនឹងអាជីវកម្មរ៉ែមាសនៅកម្ពុជា ធ្វើជាឯកសារយោងសម្រាប់បំពេញការសិក្សាកំណត់នូវសន្ទស្សន៍អភិបាលកិច្ចធនធានរ៉ែមាសរបស់ប្រទេសកម្ពុជា ឆ្នាំ២០១៦ ធ្វើឡើងដោយវិទ្យាស្ថាន NRGI

ឯកឧត្តមជាទីគោរព!

ខ្ញុំបាទកំពុងធ្វើការសិក្សាស្រាវជ្រាវជូនវិទ្យាស្ថាន NRGI (Natural Resources Governance Institute) ដើម្បីកំណត់នូវសន្ទស្សន៍អភិបាលកិច្ចធនធានរ៉ែមាសរបស់ប្រទេសកម្ពុជា ឆ្នាំ២០១៦។ ការសិក្សានេះផ្អែកជាសំខាន់លើព័ត៌មានដែលមានជាសាធារណៈ ឬ ដែលអាចទទួលបានតាមការស្នើសុំ ដោយឥតបង់ថ្លៃអ្វីទាំង អស់។ ខ្ញុំសូមជម្រាបឯកឧត្តមបន្ថែមទៀតថា កន្លងមកវិទ្យាស្ថាន NRGI ធ្លាប់បានធ្វើការសិក្សាកំណត់នូវសន្ទស្សន៍អភិបាលកិច្ចធនធានរ៉ែកម្ពុជាម្តងរួចមកហើយកាលពីឆ្នាំ ២០១៣ ដែលលទ្ធផលនៃការសិក្សានោះមានផ្សព្វផ្សាយនៅលើគេហទំព័ររបស់ NRGI (http://www.resourcegovernance.org/our-work/country/cambodia)។ ឆ្នាំនេះសម្រាប់ប្រទេសកម្ពុជា វិទ្យាស្ថាន NRGI បានកំណត់យកប្រទេសរ៉ែមាស ជាគោលដៅនៃការសិក្សាកំណត់សន្ទស្សន៍អភិបាលកិច្ចធនធានរ៉ែកម្ពុជា។ ការស្រាវជ្រាវប្រមូលព័ត៌មាន និងឯកសារពាក់ព័ន្ធសម្រាប់ការសិក្សានេះទាមទារឱ្យចប់រួចរាល់យ៉ាងយូរត្រឹមចុងខែមេសា

ឆ្នាំ២០១៦ នេះ។ ដូច្នេះដើម្បីមានឯកសារយោងគ្រប់គ្រាន់ ឬ ច្បាស់លាស់ ខ្ញុំបាទសូមស្នើសុំនូវព័ត៌មាន និងឯកសារពាក់ព័ន្ធប្រសិនបើមានដូចខាងក្រោម÷

1. បែបបទ និងលក្ខណៈវិនិច្ឆ័យក្នុងការជ្រើសរើសក្រុមហ៊ុន សម្រាប់ផ្តល់សម្បទានរ៉ែមាស ឬ អាជ្ញាប័ណ្ណរ៉ែមាស
2. បញ្ជីកិច្ចសន្យាសម្បទានរ៉ែមាស និងអាជ្ញាប័ណ្ណអាជីវកម្មរ៉ែមាសទាំងអស់ (ព្រមទាំងច្បាប់ចម្លងនៃកិច្ចសន្យា ឬ អាជ្ញាប័ណ្ណអាជីវកម្មរ៉ែមាស)
3. អត្តសញ្ញាណ និងពត៌មានលម្អិតនៃសម្បទានិករ៉ែមាស ឬ អ្នកកាន់អាជ្ញាប័ណ្ណរ៉ែមាសទាំងអស់
4. បញ្ជីបែងចែកតំបន់ ឬ ប្លុកនៃអាជ្ញាប័ណ្ណរ៉ែមាស
5. បញ្ជីឈ្មោះក្រុមហ៊ុន ឬ បុគ្គលដែលមានផលប្រយោជន៍ក្នុងកិច្ចសន្យាសម្បទានរ៉ែមាស ឬ អាជ្ញាប័ណ្ណរ៉ែមាស
6. ទំហំ និងតម្លៃនៃកំណប់រ៉ែមាស ផលិតកម្មរ៉ែមាស និងការនាំចេញធនធានរ៉ែមាសទាំងអស់ក្នុងប្រទេស
7. ទំហំ និងតម្លៃនៃកំណប់រ៉ែមាស ផលិតកម្មរ៉ែមាស និងការនាំចេញធនធានរ៉ែមាសតាមគម្រោងរ៉ែមាសនីមួយៗ
8. តើការបង់ចំណូលពីធនធានរ៉ែមាស តើតម្រូវឱ្យបង់របៀបណា? តើចំណូលជាក់ស្តែងដែលបានទទួលពីសម្មភាពធនធានរ៉ែមាស មានប៉ុន្មាន?
9. តើមានការផ្ទេរចំណូលពីធនធានរ៉ែ ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិឬទេ? (ប្រសិនបើមាន សូមផ្តល់ច្បាប់ចម្លងនៃលិខិតបទដ្ឋានគិតយុត្ត ឯកសាគោលនយោបាយ ឬ និងរបាយការណ៍ពាក់ព័ន្ធនឹងការផ្ទេរចំណូលនោះ)
10. តើមានការប៉ាន់ប្រមាណចំណូលពីធនធានរ៉ែដែលអាចទាញយកបាននាពេលអនាគត ជាផ្នែកមួយនៃចំណូលថវិកាជាតិ ឬទេ?

11. តើមានបង្កើតមូលនីធិធនធានធម្មជាតិ (មូលនីធិធនធានរ៉ែ ក្រៅពីប្រេងកាត និងឧស្ម័ន) និងវិធាន សម្រាប់ការប្រើប្រាស់ ឬ ការវិនិយោគនូវមូលនីធិធនធានរ៉ែ ឬទេ? (ប្រសិនបើមាន សូមផ្តល់ច្បាប់ចម្លងនៃលិខិតបទដ្ឋានគិតយុត្ត ឯកសាគោលនយោបាយ ឬ និងរបាយការណ៍ពាក់ព័ន្ធនឹងមូលនីធិនោះ)។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមមេត្តាសម្រួល និងអនុញ្ញាតឱ្យមន្ត្រីក្រោមឱវាទរបស់ឯកឧត្តម ផ្តល់នូវព័ត៌មាន និងឯកសារពាក់ព័ន្ធតាមលទ្ធភាពជាក់ស្តែង។ សូមអរគុណ។

ភ្នំពេញ, ថ្ងៃទី ០៩ មេសា ២០១៦

ញាន សុមុន្និន្ទ

Tel: ០១២ ៥៣ ៩៧ ១៤

somunin2012@gmail.com